ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងទេសចរណ៍

លេខ ០៧១ ទបក

រាជធានីភ្នំពេញ, ថ្ងៃទី២៤ ខែ មីនា ឆ្នាំ២០១៦

# ប្រកាស

## ស្តីពី

## នីតិវិធីផ្តល់វិញ្ញាបនបត្រ និងស្លាកសញ្ញាស្តង់ដាសណ្ឋាគារបៃតងកម្ពុជា

## រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី ២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ៣៤ អនក្រ.បក. ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក. ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០០០ ស្តីពីការកែសម្រួលមុខងារ និងភារៈកិច្ច និងការបង្កើតក្រុមអ្នកច្បាប់ និងនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនិងអាស៊ាន នៃក្រសួងទេសចរណ៍
- យោងតាមសំណូមពរចាំបាច់នៃការងាររបស់ក្រសួងទេសចរណ៍។

## សម្រេច

## ជំពូកទី១

## បទបញ្ញត្តិទូទៅ

**ប្រការ ១.-**

ប្រកាសនេះ មានវិសាលភាពអនុវត្តគ្រប់សណ្ឋាគារទាំងអស់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ២ .-**

ប្រកាសនេះ មានគោលបំណងកំណត់អំពីនីតិវិធីក្នុងការផ្តល់វិញ្ញាបនបត្រ និងស្លាកសញ្ញាស្តង់ដាសណ្ឋាគារបៃតងកម្ពុជា ដល់សណ្ឋាគារទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ៣ .-**

ប្រកាសនេះ មានគោលដៅជម្រុញឱ្យដំណើរការអាជីវកម្មសណ្ឋាគារទាំងអស់យកចិត្តទុកដាក់ ក្នុងការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព និងដើម្បីពង្រឹងគុណភាពសណ្ឋាគារ។

**ប្រការ ៤ .-**

ក្រសួងទេសចរណ៍ មានភារកិច្ចរៀបចំត្រួតពិនិត្យ និងវាយតម្លៃ ដើម្បីផ្តល់វិញ្ញាបនបត្រ និងស្លាកសញ្ញាស្តង់ដាសណ្ឋាគារបៃតងកម្ពុជា ដល់សណ្ឋាគារទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២

## លក្ខខណ្ឌផ្តល់វិញ្ញាបនបត្រ និងស្លាកសញ្ញាស្តង់ដាសណ្ឋាគារបៃតងកម្ពុជា

**ប្រការ ៥ .-**

ម្ចាស់ ឬអ្នកគ្រប់គ្រងសណ្ឋាគារ មានកាតព្វកិច្ចដាក់ពាក្យស្នើសុំវិញ្ញាបនបត្រ និងស្លាកសញ្ញាស្តង់ដាសណ្ឋាគារបៃតងកម្ពុជា។ ការដាក់ពាក្យស្នើសុំសណ្ឋាគារបៃតងកម្ពុជា អាចធ្វើបានតាមរយៈការដាក់ពាក្យដោយផ្ទាល់នៅក្រសួងទេសចរណ៍ ឬមន្ទីរទេសចរណ៍រាជធានី-ខេត្ត ឬតាមប្រព័ន្ធអនឡាញ (Online)។

**ប្រការ ៦ .-**

សណ្ឋាគារ ដែលមានចំណាត់ថ្នាក់ផ្កាយ ត្រូវធ្វើការត្រួតពិនិត្យ និងវាយតម្លៃទៅលើតែលក្ខណវិនិច្ឆ័យចាំបាច់ដែលបានកំណត់នៅក្នុងស្តង់ដាសណ្ឋាគារបៃតងកម្ពុជា។

សណ្ឋាគារ ដែលគ្មានចំណាត់ថ្នាក់ផ្កាយ ត្រូវធ្វើការត្រួតពិនិត្យ និងវាយតម្លៃលម្អិតទៅតាមលក្ខណវិនិច្ឆ័យ ដែលបានកំណត់នៅក្នុងស្តង់ដាសណ្ឋាគារបៃតងកម្ពុជា។

ម្ចាស់ ឬអ្នកគ្រប់គ្រងសណ្ឋាគារ ដែលមកដាក់ពាក្យស្នើសុំវិញ្ញាបនបត្រ និងស្លាកសញ្ញាស្តង់ដាសណ្ឋាគារបៃតងកម្ពុជា ត្រូវភ្ជាប់មកជាមួយនូវ៖

- ពាក្យស្នើសុំវាយតម្លៃដំណើរការអាជីវកម្មសណ្ឋាគារ សម្រាប់ស្តង់ដាសណ្ឋាគារបៃតងកម្ពុជា
- អាជ្ញាបណ្ណទេសចរណ៍មានសុពលភាព ដែលចេញដោយក្រសួងទេសចរណ៍ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ
- ឯកសារបញ្ជាក់អំពីកម្រិតគុណភាពចំណាត់ថ្នាក់សណ្ឋាគារ ដែលចេញដោយក្រសួងទេសចរណ៍ (បើមាន)
- របាយការណ៍ស្តីពីការអនុវត្តស្តង់ដាសណ្ឋាគារបៃតងរបស់បេក្ខភាព
- កិច្ចសន្យាគោរព និងអនុវត្តច្បាប់ស្តីពីទេសចរណ៍ និងច្បាប់រដ្ឋនានា
- រូបថត ៤x៦ ចំនួន ០៣ សន្លឹក
- អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន។

**ប្រការ ៧ .-**

ក្រោយពីទទួលបានការសម្រេចទទួលស្គាល់ថា ដំណើរការអាជីវកម្មសណ្ឋាគារសមស្របទៅនិងស្តង់ដាសណ្ឋាគារបៃតងកម្ពុជាពីក្រសួងទេសចរណ៍។ ម្ចាស់ ឬអ្នកគ្រប់គ្រងសណ្ឋាគារ នឹងទទួលបាននូវ ៖

- វិញ្ញាបនបត្របញ្ជាក់ពីស្តង់ដាសណ្ឋាគារបៃតងកម្ពុជា
- ស្លាកសញ្ញាស្តង់ដាសណ្ឋាគារបៃតងកម្ពុជា។

**ប្រការ ៨ ._**

វិញ្ញាបនបត្រ និងស្លាកសញ្ញាស្តង់ដាសណ្ឋាគារបៃតង ដែលត្រូវបានចេញដោយក្រសួងទេសចរណ៍ មានសុពលភាពរយៈពេល ០២ (ពីរ) ឆ្នាំ។

**ប្រការ ៩ ._**

ការដាក់ពាក្យស្នើសុំវិញ្ញាបនបត្រ និងស្លាកសញ្ញាស្តង់ដារសណ្ឋាគារបៃតងកម្ពុជា ត្រូវបង់ថវិកា ៣០០,០០០ (បីរយពាន់) រៀលគត់។

**ប្រការ ១០ ._**

ការផ្តល់ និងការដកហូតវិញ្ញាបនបត្រ និងស្លាកសញ្ញាស្តង់ដាសណ្ឋាគារបៃតងកម្ពុជា ជាសមត្ថកិច្ចរបស់ក្រសួងទេសចរណ៍។

**ប្រការ ១១ ._**

សណ្ឋាគារ ដែលទទួលបាននូវវិញ្ញាបនបត្រ និងស្លាកសញ្ញាស្តង់ដាសណ្ឋាគារបៃតងកម្ពុជារួចហើយ ទើបមានសិទ្ធិដាក់ពាក្យស្នើសុំវិញ្ញាបនបត្រ និងស្លាកសញ្ញាស្តង់ដាសណ្ឋាគារបៃតងអាស៊ាន ។

**ប្រការ ១២ ._**

សណ្ឋាគារទាំងឡាយ មិនអាចប្រើប្រាស់វិញ្ញាបនបត្រ និងស្លាកសញ្ញាស្តង់ដាសណ្ឋាគារបៃតងកម្ពុជាសម្រាប់សាខាដ៏ទៃផ្សេងទៀតបានឡើយ។

**ប្រការ ១៣ ._**

សណ្ឋាគារទាំងឡាយ ត្រូវដាក់តាំងវិញ្ញាបនបត្រ និងស្លាកសញ្ញាស្តង់ដាសណ្ឋាគារបៃតងកម្ពុជានៅកន្លែងទទួលភ្ញៀវ ដែលអាចមើលឃើញច្បាស់។

**ប្រការ ១៤ ._**

វិញ្ញាបនបត្រ និងស្លាកសញ្ញាស្តង់ដាសណ្ឋាគារបៃតងកម្ពុជា ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងទេសចរណ៍។ សោហ៊ុយចំណាយលើការផលិតស្លាកសញ្ញាស្តង់ដាសណ្ឋាគារបៃតងកម្ពុជា ជាបន្ទុករបស់ម្ចាស់សណ្ឋាគារ។

**ប្រការ ១៥ ._**

សេចក្តីលម្អិតអំពីស្តង់ដាសណ្ឋាគារបៃតងកម្ពុជា ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងទេសចរណ៍។

## ជំពូកទី៣

## សិទ្ធិ និងភារកិច្ចរបស់ប្រតិបត្តិករទេសចរណ៍

**ប្រការ ១៦ ._**

ម្ចាស់ ឬអ្នកគ្រប់គ្រងសណ្ឋាគារទាំងអស់ ត្រូវមានកាតព្វកិច្ចដូចតទៅៈ

ក. អនុវត្តតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន ដែលពាក់ព័ន្ធនឹងស្តង់ដា ក្រមប្រតិបត្តិវិជ្ជាជីវៈ ក្រមសីលធម៌វិជ្ជាជីវៈ និងលក្ខខណ្ឌនានាដែលកំណត់ដោយក្រសួងទេសចរណ៍

ខ. អនុវត្តតាមច្បាប់ និងបទប្បញ្ញត្តិទាំងឡាយ ដែលប៉ះពាល់ទៅលើ ឬទទួលរងការប៉ះពាល់ដោយវិស័យទេសចរណ៍ ដូចជា ការកំណត់នគរូបនីយកម្ម ការសាងសង់អាគារ សុវត្ថិភាព អគ្គីភ័យ សន្តិសុខសណ្តាប់ធ្នាប់សាធារណៈ បរិស្ថាន សុខភាព អនាម័យ ម្ហូបអាហារ ការងារ កាតព្វកិច្ចពន្ធ គណនេយ្យ និងហិរញ្ញវត្ថុ ការ

ការពារមរតកវប្បធម៌ មរតកធម្មជាតិ

គ. ការពារប្រយោជន៍ជាតិ និងប្រយោជន៍ទេសចរ និងចូលរួមចំណែកក្នុងការថែរក្សាធនធានធម្មជាតិ បរិស្ថានបៃតង មិនបំពុល ឬមិនបំផ្លាញបរិស្ថាន ការពារ និងអភិរក្ស សម្បត្តិវប្បធម៌ សិល្បៈប្រពៃណី ទំនៀមទម្លាប់របស់ប្រជាពលរដ្ឋខ្មែរ ក្នុងរាល់សកម្មភាពទេសចរណ៍របស់ខ្លួន

ឃ. ផ្តល់ដល់ទេសចរនូវព័ត៌មានពិតច្បាស់លាស់ និងទទួលខុសត្រូវផ្តល់សេវាកម្ម ដូចដែលបានសន្យា ព្រមទាំងមានវិធានការសមស្របដើម្បីថែទាំទ្រព្យសម្បត្តិ ការពារសន្តិសុខ និងសុវត្ថិភាពដល់ទេសចរក្នុងពេល ដែលទេសចរស្ថិតក្រោមការគ្រប់គ្រងរបស់ខ្លួន

ង. ប្តឹង ឬរាយការណ៍ជាបន្ទាន់ទៅនគរបាលទេសចរណ៍ អាជ្ញាធរមានសមត្ថកិច្ច ឬសមត្ថកិច្ចទេសចរណ៍ ដែលនៅជិតបំផុត ក្នុងករណីដឹង ឬមានការសង្ស័យថា មានការប្រព្រឹត្តបទល្មើស ការជួញដូរ និងការប្រើប្រាស់គ្រឿងញៀន ការជួញដូរនិងការបង្ខាំងមនុស្ស ការជួញដូរកុមារ ការធ្វើអាជីវកម្មផ្លូវភេទ ការផ្សព្វផ្សាយរូបភាព និងសម្ភារៈអាសអាភាស ឬប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌផ្សេងៗទៀត

ច. អ្នកគ្រប់គ្រងសណ្ឋាគារ ត្រូវកត់ត្រាទុកអត្តសញ្ញាណរបស់អតិថិជន និងព័ត៌មានផ្សេងៗទៀត នៅពេលចូលស្នាក់នៅ

ឆ. សហការនៅក្នុងកិច្ចអធិការកិច្ច ដូចមានចែងក្នុងមាត្រា៦០ នៃច្បាប់ស្តីពីទេសចរណ៍

ជ. ប្រតិបត្តិស្របតាមក្រមសីលធម៌របស់អង្គការទេសចរណ៍ពិភពលោកឱ្យបានល្អ

ឈ. អនុវត្តឱ្យបានខ្ជាប់ខ្ជួននូវលក្ខខណ្ឌដែលមានចែងក្នុងមាត្រា៣៩ នៃច្បាប់ស្តីពីទេសចរណ៍

ញ. អនុវត្តតាមវិធានការធានាគុណភាព ដែលចេញដោយក្រសួងទេសចរណ៍ និងមិនប្រឌិតព័ត៌មានអំពីស្លាកសញ្ញាស្តង់ដាសណ្ឋាគារបៃតងកម្ពុជា ដែលមិនត្រឹមត្រូវឡើយ

ដ. មានគំនិតផ្តួចផ្តើម ឬចូលរួមកាត់បន្ថយភាពក្រីក្រភាពជាក់ស្តែង តាមរយៈសកម្មភាពសង្គម

ឋ. ចូលរួម និងគាំទ្រគោលនយោបាយទេសចរណ៍បៃតង **"ទេសចរណ៍ម្នាក់ ដើមឈើមួយដើម"** ដែលកំណត់ដោយក្រសួងទេសចរណ៍

ឌ គាំទ្រ និងចូលរួមយុទ្ធនាការឃោសនាផ្សព្វផ្សាយ **"កម្ពុជា ៖ ព្រះរាជាណាចក្រអច្ឆរិយៈ"** និងចលនាប្រឡងប្រណាំង **"ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ បដិសណ្ឋារកិច្ចល្អ"** និងជម្រុញចលនាទេសចរណ៍ក្នុងស្រុកឱ្យកាន់តែមានកំនើនខ្ពស់ ។

**ប្រការ ១៧ ._**

ប្រតិបត្តិករទេសចរណ៍ ដែលជាម្ចាស់ជ័យលាភីស្លាកសញ្ញាស្តង់ដាសណ្ឋាគារបៃតងកម្ពុជា នឹងទទួលបាននូវបុព្វសិទ្ធិ និងការលើកទឹកចិត្តផ្សេងៗ ដូចដែលមានកំណត់ក្នុងប្រការ ២ នៃប្រកាសលេខ ១៧៨ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការលើកទឹកចិត្តចំពោះជ័យលាភីនៃការប្រឡងប្រណាំងរង្វាន់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** សម្រាប់ធុរកិច្ចបៃតងក្នុងវិស័យទេសចរណ៍។

## ជំពូកទី៤

## ទោសប្បញ្ញត្តិ

**ប្រការ ១៨ ._**

សណ្ឋាគារ ដែលប្រើប្រាស់ស្លាកសញ្ញាស្តង់ដាសណ្ឋាគារបៃតង ដោយមិនបានទទួលស្គាល់ពីក្រសួងទេសចរណ៍ នឹងត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ចំនួន ៤,០០០,០០០(បួនលាន)រៀល។ ប្រសិនបើសណ្ឋាគារ មិនបានបង់ប្រាក់ពិន័យតាមកាលកំណត់នោះទេ ទំហំទឹកប្រាក់ពិន័យត្រូវអនុវត្តទ្វេដង។

ករណីនៅតែមិនព្រមទទួលការពិន័យនេះទេ ភាគីសណ្ឋាគារត្រូវទទួលខុសត្រូវចំពោះបទល្មើស និងទោសប្បញ្ញត្តិនៃច្បាប់ស្តីពីទេសចរណ៍ និងច្បាប់នានាជាធរមាន។

**ប្រការ ១៩ .-**

ម្ចាស់ ឬ អ្នកគ្រប់គ្រងសណ្ឋាគារ និងមូលដ្ឋានអាជីវកម្មសេវាកម្មស្នាក់នៅទេសចរណ៍ ដែលប្រព្រឹត្តល្មើសនឹងមាត្រា ១៦ នៃប្រកាសនេះ នឹងត្រូវដកហូត ឬព្យួរវិញ្ញាបនបត្រ និងស្លាកសញ្ញាស្តង់ដាសណ្ឋាគារបៃតងកម្ពុជា។

## ជំពូកទី៥

## អន្តរប្បញ្ញត្តិ

**ប្រការ ២០ .-**

សណ្ឋាគារទាំងអស់ ដែលបានទទួលវិញ្ញាបនបត្រ និងស្លាកសញ្ញាស្តង់ដាសណ្ឋាគារបៃតងអាស៊ាន អាចបន្តប្រើប្រាស់ រហូតដល់សុពលភាពដែលបានកំណត់ រួចត្រូវអនុវត្តតាមប្រការ១១ នៃប្រកាសនេះ នៅពេលបន្តសុពលភាពវិញ្ញាបនបត្រ និងស្លាកសញ្ញាស្តង់ដាសណ្ឋាគារបៃតងអាស៊ាន។

## ជំពូកទី៦

## អវសានប្បញ្ញត្តិ

**ប្រការ ២១ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយទៅនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ២២ .-**

រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកទេសចរណ៍ នាយកខុទ្ទកាល័យ អធិការ ប្រធានក្រុមអ្នកច្បាប់ គ្រប់ប្រធាននាយកដ្ឋាន និងប្រធានមន្ទីរទេសចរណ៍រាជធានី-ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រដ្ឋមន្ត្រី

ថោង ខុន

**កន្លែងទទួល:**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- សាលារាជធានី-ខេត្ត

  *"ដើម្បីជូនជ្រាប"*
- មន្ទីរទេសចរណ៍រាជធានី ខេត្ត
- សហព័ន្ធទេសចរណ៍កម្ពុជា

  *"ដើម្បីមុខការ"*
- សមាគមសណ្ឋាគារកម្ពុជា
- អាជីវកម្មសណ្ឋាគារ

  *"ដើម្បីសហការ និងអនុវត្ត"*
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ